**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៤១៣.០១៩.០១៩ ប្រកាសពត៌មាន

*ថ្ងៃព្រហស្បតិ៍ ១៣រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩*

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី "ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) ដាក់ឱ្យដំណើរការ មូលនិធិសញ្ញាប័ណ្ណបៃតងសម្រាប់ធនាគារកណ្តាល"

នៅថ្ងៃព្រហស្បតិ៍ ១៣រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) បានដាក់ឱ្យប្រើប្រាស់នូវមូលនិធិបើកចំហសម្រាប់ការវិនិយោគរបស់ធនាគារកណ្តាលទៅលើសញ្ញាប័ណ្ណបៃតង ដើម្បីឆ្លើយតបនឹងការកើនឡើងនៃតម្រូវការសម្រាប់ការវិនិយោគដែលមិនប៉ះពាល់ដល់បរិស្ថាន។ គំនិតផ្តួចផ្តើមនេះនឹងជួយដល់ធនាគារកណ្តាលក្នុងការដាក់បញ្ចូលគោលការណ៍បរិស្ថានប្រកបដោយចីរភាពទៅក្នុងការគ្រប់គ្រងទុនបម្រុង។

ធនាគារជាតិនៃកម្ពុជា មានសេចក្តីសោមនស្សដោយបានក្លាយជាសមាជិកនៃគណៈកម្មាធិការប្រឹក្សាយោបល់ ដែលបានផ្តល់ការគាំទ្រដល់គំនិតផ្តួចផ្តើមនេះ ហើយធនាគារជាតិនៃកម្ពុជាក៏ជាអ្នកវិនិយោគដំបូងសម្រាប់សញ្ញាប័ណ្ណដែលផ្តល់ហិរញ្ញប្បទានប្រកបដោយចីរភាពនិងនវានុវត្តភាពនេះផងដែរ។

ខណៈដែលបម្រែបម្រួលអាកាសធាតុត្រូវបានមើលឃើញថាជាប្រភពចម្បងនៃភាពមិនច្បាស់លាស់សម្រាប់កំណើនសេដ្ឋកិច្ច និងអាចផ្តល់ផលប៉ះពាល់ជាអវិជ្ជមានទៅលើកត្តាសង្គម និងបរិស្ថាន ការផ្តល់ហិរញ្ញប្បទានបៃតងអាចផ្តល់នូវជម្រើសដែលមានគុណប្រយោជន៍ជាច្រើនសម្រាប់វិនិយោគិន ដើម្បីជួយការពារភពផែនដី។ កាលានុវត្តភាពដែលអាចទទួលបានជោគជ័យជាងគេគឺសញ្ញាប័ណ្ណបៃតង ដែលដើរតួនាទីសំខាន់ក្នុងការបង្កើនការយល់ដឹងនិងកសាងសមត្ថភាពជំនាញសម្រាប់វិនិយោគិនលើបញ្ហាបរិស្ថាននិងអាកាសធាតុ។ ការវិនិយោគលើសញ្ញាប័ណ្ណបៃតងមិនត្រឹមតែបង្កើតប្រាក់ចំណេញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ផលវិជ្ជមានសម្រាប់បរិស្ថានទៀតផង ដោយសារតែសញ្ញាប័ណ្ណនេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងបៃតង ឬធុរកិច្ចដែលផ្តល់ផលវិជ្ជមានដល់បរិស្ថាន ហើយជាលទ្ធផលធ្វើឱ្យនវានុវត្តភាពបៃតងកើនឡើង និងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព។

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ដោយសង្កេតឃើញពីកម្រិតទាបនៃហានិភ័យហិរញ្ញវត្ថុនិងផលចំណេញនៃការវិនិយោគលើសញ្ញាប័ណ្ណបៃតង ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា បានផ្តល់យោបល់លើការដាក់ចេញនូវគំនិតផ្តួចផ្តើមសញ្ញាប័ណ្ណបៃតងរបស់ BIS សម្រាប់ធនាគារកណ្តាលថា "ក្នុងនាមជាធនាគារកណ្តាល តួនាទីរបស់យើងគឺចូលរួមកាត់បន្ថយហានិភ័យហិរញ្ញវត្ថុដែលបណ្តាលមកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើសេដ្ឋកិច្ច ស្ថានភាពសង្គម និងបរិស្ថាន។ យើងជឿជាក់ថា ស្ថាប័ន ក៏ដូចជា បុគ្គលនីមួយៗ នៃប្រទេសអភិវឌ្ឍន៍ ឬកំពុងអភិវឌ្ឍន៍ក្តី អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកដល់កំណើនប្រកបដោយសមធម៌និងចីរភាព តាមរយៈការកាត់បន្ថយល្បឿននៃការប្រែប្រួលអាកាសធាតុយ៉ាងឆាប់រហ័សនិងហានិភ័យនៃបម្រែបម្រួលនេះ។ យើងលើកទឹកចិត្តយ៉ាងខ្លាំងដល់គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ឱ្យដាក់ចេញនូវគោលនយោបាយដែលលើកកម្ពស់ហិរញ្ញប្បទានបៃតងនិងគាំទ្រដល់ការវិនិយោគដែលផ្តល់ផលវិជ្ជមានដល់បរិស្ថាន។"

សូមទំនាក់ទំនង៖
ធនាគារជាតិនៃកម្ពុជា
នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ
ទូរសព្ទ៖ ០២៣ ៩៩០ ១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh